ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សាកលវិទ្យាល័យ អង្គរខេមរា

# ANGKOR KHEMARA UNIVERSITY

## ដេប៉ាតឺម៉ង់ ៖ អក្សរសាស្ត្រខ្មែរ

## មុខវិជ្ជា ៖ រចនាបថវិទ្យា( វិធីសាស្ត្រសរសេរតែងសេចក្តី )

### ប្រធានបទស្តីពី ៖ តែងសេចក្តីអត្ថាធិប្បាយពន្យល់

**ប្រធាន៖**

"រឿងរាមកេរ្តិ៍មានលក្ខណៈតម្លៃពិសេសក្នុងអក្សរសិល្ប៍ខ្មែរ"។


បង្រៀននិងណែនាំដោយ៖ អនុ.ហួន ស៊ីឡុន

រៀបរៀងដោយ៖ ឌី ជីវ័ន្ត ( និស្សិតអក្សរសាស្ត្រខ្មែរ ជំនាន់ទី១៤ សាខាពោធិ៍សាត់ )



*អត្តលេខ ៖ #AKU01-B-00155 PS*


ព.ស ២៥៦៧ ឆ្នាំសិក្សា២០២២-២០២៣ គ.ស ២០២៣

# អារម្ភកថា

តែងសេចក្តីជាមុខវិជ្ជាដ៏សំខាន់មួយក្នុងចំណោមមុខវិជ្ជាផ្សេងៗទៀត។ ប្រសិនបើគ្រាន់តែចេះភាសាខ្មែរបន្តិចបន្តួច ចេះចាំរឿងក្នុងអក្សរសិល្ប៍បានខ្លះៗ នោះគេមិនអាចសរសេរតែងសេចក្តីបានល្អទេ។ ផ្ទុយទៅវិញ ការសរសេរតែងសេចក្តីឱ្យបានល្អនោះ ទាមទារឱ្យអ្នកសរសេរមានចំណេះដឹងផ្សេងៗជាច្រើនទាក់ទងនឹងចំណេះដឹងខាងផ្នែកអក្សរសាស្ត្រជាតិ វេយ្យាករណ៍ ប្រវត្តិវិទ្យា បរិស្ថាន សីលធម៌ពលរដ្ឋវិជ្ជា បទពិសោធក្នុងការរស់នៅប្រចាំថ្ងៃជាដើម។ ពោលគឺការសរសេរតែងសេចក្តីបានល្អ ត្រូវមានចំណេះដឹង ឬវប្បធម៌ទូទៅទូលំទូលាយ ពិសេសនោះគឺចេះចាំអក្សរសិល្ប៍បានច្បាស់លាស់។

កិច្ចការស្រាវជ្រាវដែលមានចំណងជើងថា "**តែងសេចក្តីអត្ថាធិប្បាយពន្យល់**" ត្រូវបានសរសេរដោយមានការយកចិត្តទុកដាក់ និងសម្រិតសម្រាំង ហើយខ្លឹមសារ និងគោលបំណងក្នុងកិច្ចការមួយនេះ គឺចង់ចូលរួមចែករំលែករវាងអ្នករៀបរៀង និងអ្នកអាន អ្នកស្តាប់ ពីបទពិសោធ ក៏ដូចជាចំណេះដឹង បំពេញឱ្យគ្នាទៅវិញទៅមក។

ម្យ៉ាងទៀតខ្ញុំជឿជាក់ថា ស្នាដៃនេះពិតជានៅមានចំណុចខ្វះខាតមួយចំនួនជាក់ ជាពុំខាន។ ប្រការនេះហើយ ខ្ញុំបាទរង់ចាំទទួលមតិការកែលម្អដោយក្តីរីករាយ ពីសំណាក់ លោកគ្រូ និងរៀមច្បង ព្រមទាំងមិត្តរួមជំនាន់ក្នុងថ្នាក់អក្សរសាស្ត្រខ្មែរ ទាំងអស់ដោយក្តីគោរព។

*តាលោសែនជ័យថ្ងៃ ចន្ទ ទី ១៧ ខែ កក្កដា ឆ្នាំ២០២៣*

# សេចក្ដីថ្លែងអំណរគុណ

ទន្ទឹមនឹងការកកើតនូវស្នាដៃឡើងបានជាលទ្ធផលនេះខ្ញុំបាទសូមសម្ដែងនូវអំណាគុណជាអនេកប្រការចំពោះ ៖

លោកឪពុក អ្នកម្ដាយនៃខ្ញុំទាំងឡាយជាបុព្វាចារ្យនឹងជាព្រះអរហន្តដ៏ប្រសើររបស់ខ្ញុំបាទដែលលោកបានផ្ដល់នៅកំណើត ហើយចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌។ ជានិច្ចកាលលោក តែងតែណែនាំចង់ឲ្យក្លាយជាគ្រាប់ពូជដ៏មានតម្លៃមួយ។

លោកគ្រូ អ្នកគ្រូទាំងអស់តាំងពីថ្នាក់បឋមសិក្សារហូតមកដែលលោកបានបង្ហាត់បង្រៀនឲ្យខ្ញុំបាទនូវទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានពោលគឺចំណេះវិជ្ជា ព្រមទាំងសីលធម៌ សុជីវធម៌ក្នុងសង្គមធ្វើឲ្យក្លាយជាធនធានដ៏មានតម្លៃមួយសម្រាប់សង្គមជាតិ។

បណ្ឌិត **នូ ចាន់សុធី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរខេមរា និងគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ ធ្វើឲ្យខ្ញុំបានទទួលបានចំណេះដឹងដ៏មានតម្លៃសម្រាប់ជួយខ្លួនឯង គ្រួសារ និងសង្គមជាតិបានមួយចំណែក។

សាស្ត្រាចារ្យក្នុងដេប៉ាតឺម៉ង់ អក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ដែលបានខិតខំប្រិតប្រៀនតម្រែតម្រង់នៅមុខវិជ្ជាទាំងឡាយក្នុងជំនាញអក្សរសាស្ត្រខ្មែរញ៉ាំងឲ្យខ្ញុំបាទទទួលនូវចំណេះដឹងយ៉ាងស្រួចស្រាល់លើជំនាញរបស់ខ្ញុំ។ ជាពិសេសសូមអរគុណជាអនេក ចំពោះសាស្ត្រាចារ្យអនុបណ្ឌិត **ឃួន ស៊ីឡុន** ដែលបង្រៀនលើមុខវិជ្ជា*រចនាបថវិទ្យា (វិធីសាស្ត្រសេរសេរតែងសេចក្ដី)* ដែលបានណែនាំកែតម្រូវលើកិច្ចការស្រាវជ្រាវមួយនេះ។

៚៚៚

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ។
- វិញ្ញាណក្ខន្ធកវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់។ ដែលបានខិតខំថែរក្សាអក្សរសាស្ត្រជាតិឱ្យរីកចម្រើនគង់វង្សរហូតមកដល់សព្វថ្ងៃ។
- វិញ្ញាណក្ខន្ធសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលព្រះអង្គបានបន្សល់ស្នាដៃដ៏វិសេសវិសាលសម្រាប់កូនខ្មែរគ្រប់ជំនាន់នោះគឺ សៀវភៅវចនានុក្រមខ្មែរ។
- វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់ខ្ញុំទាំងអស់។

សូមជួយទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

# <u>មាតិកា</u>

I . គម្រោងតែងសេចក្តី ...................................................................... ទំព័រទី០១-០៣។

II. សេចក្តីអត្ថាធិប្បាយ ...................................................................... ទំព័រទី០៤-០៧។

III. ឯកសារយោង ............................................................................. ទំព័រទី០៨។

# I. គម្រោងតែង

## ក. សេចក្តីផ្តើម

– លំនាំបញ្ហា៖ រាល់ស្នាដៃអក្សរសិល្ប៍ទាំងអស់សុទ្ធតែបានបង្កប់នូវអត្ថន័យ គុណតម្លៃជាច្រើន ទៅតាមប្រភេទ និងចលនារបស់អក្សរសិល្ប៍នីមួយៗ។ ហើយនៅក្នុងចំណោមចលនាអក្សរសិល្ប៍ទាំងនោះ យើងឃើញចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយមតែងតែបង្កប់នូវតម្លៃល្អៗរបស់ខ្មែរយើងជាច្រើនដែលជាអត្តសញ្ញាណជាតិ ហើយដែលសុទ្ធសឹងជា ពុទ្ធិ និងជាគតិដ៏ពិសេសៗភ្ជាប់មកជាមួយស្នាដៃអក្សរសិល្ប៍ខ្មែរយើង តួយ៉ាងនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរយើងជាដើម។

– ចំណូលបញ្ហា៖ អាស្រ័យដូចហេតុនេះហើយទើបមានប្រធានលើកឡើងថា "រឿងរាមកេរ្តិ៍មានលក្ខណៈតម្លៃពិសេសក្នុងអក្សរសិល្ប៍ខ្មែរ"។

– ចំណោទបញ្ហា៖ តើប្រធានដែលបានលើកឡើងខាងលើមានអត្ថន័យដូចម្តេចខ្លះ?

## ខ. តួសេចក្តី

– ឃ្លាភ្ជាប់សេចក្តី៖ ដើម្បីជាប្រទីបបំភ្លឺដល់ការបកស្រាយគំនិតប្រធានខាងលើឱ្យលម្អិត ស៊ីជម្រៅ យើងគួរយល់ន័យនៃពាក្យគន្លឹះជាមុនសិន។

– ពន្យល់ពាក្យគន្លឹះ

  + លក្ខណៈ គឺជាគ្រឿងសម្គាល់នៃអត្តសញ្ញាណ បង្ហាញឱ្យឃើញ។

  + តម្លៃពិសេស សំដៅទៅលើអ្វីៗដែលល្អក្រៃលែង ដែលមានប្រយោជន៍ដ៏ថ្លៃថ្លា។

  + អក្សរសិល្ប៍ មានន័យថា កម្រងអត្ថបទទាំងឡាយដែលតាក់តែងឡើងប្រកបដោយសិល្បវិធីរបស់អ្នកនិពន្ធ។

– ពន្យល់ន័យប្រធាន

ដូចនេះអត្ថន័យប្រធានមានន័យយ៉ាងខ្លីថារឿងរាមកេរ្តិ៍បង្ហាញឱ្យឃើញអត្តសញ្ញាណដែលល្អៗ និងមានប្រយោជន៍នៅក្នុងកម្រងអត្ថបទដែលតាក់តែងឡើងប្រកបដោយសិល្បវិធី របស់អ្នកនិពន្ធខ្មែរយើង។

– បកស្រាយប្រធាន

+ បង្ហាញពីការអប់រំ

+ បង្ហាញពីទំនៀមទម្លាប់( ច្រត់ព្រះនង្គ័ល ពិធីអភិសេក ការប្រើប្រាស់កោដ្ឋ )

+ ការផ្ទេររាជ្យ

+ គោរពពាក្យសច្ចៈ

+ ប្រកាន់ធម៌អហិង្សា

+ បង្ហាញពីទឹកចិត្តម្ដាយមានចំពោះកូន

+ ស្រឡាញ់បងប្អូន

+ តម្លៃនៃសេចក្ដីស្នេហា

+ ការចេះជួយយកអាសារគ្នា

+ បង្ហាញពីក្បួរទស្សន៍ទាយ

+ ...

– សរុបមតិ៖ សរុបសេចក្ដីមក រឿងរាមកេរ្តិ៍ពិតជាមានលក្ខណៈតម្លៃពិសេសក្នុងអក្សរសិល្ប៍ខ្មែរយ៉ាសជ្រាវជ្រៅ ហើយបានបង្ហាញពីទំនៀមទម្លាប់ដែរខ្មែរយើងមានតាំងពីបុរាណកាលមក ការគោរពពាក្យសច្ចៈ ការទស្សន៍ទាយ និងការអប់រំរៀនសូត្រខាង សិល្ប៍សាស្ត្រ ទាំងនេះគឺបង្ហាញពីតម្លៃដែលមានលក្ខណៈ មួយជាខ្មែរក្នុងអក្សរសិល្ប៍ខ្មែរ។

## គ. បញ្ចាប់សេចក្ដី

– វាយតម្លៃប្រធាន៖ ឆ្លងតាមរយៈការបកស្រាយប្រធានដែលបានលើកឡើងខាងលើ និងលើកអំណះអំណាងមកបញ្ជាក់រួចមក យើងឃើញថាប្រធានពិតជាល្អ ព្រោះបានបង្ហាញពីលក្ខណៈពិសេសៗតាមរយៈរឿងរាមកេរ្តិ៍ដែលមានតម្លៃក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ។ ហើយបានបង្កប់នូវតម្លៃអប់រំ ដែលសុទ្ធតែជាដំបូន្មានល្អៗ សម្រាប់ជាគតិដល់ការរិះគិតពិចារណាក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងម្នាក់ៗនូវអ្វីដែលគួរធ្វើ សម្រាប់ខ្លួនឯង គ្រួសារនិង សង្គមជាតិ។

– មតិផ្ទាល់ខ្លួន៖ ដូចនេះក្នុងនាមយើងជា សិស្សនិស្សិតយើងគប្បីត្រូវតែខិតខំសិក្សារៀនសូត្រ និងអានសៀវភៅឱ្យបានច្រើន ពិសេសនោះគឺអាននូវស្នាដៃ អក្សរសិល្ប៍ខ្មែរយើង

ដើម្បីយល់ដឹងពីគុណតម្លៃនៃអក្សរសិល្ប៍ ហើយទន្ទឹមនឹងការអានយើងក៏ត្រូវចូលរួមថែរក្សាស្នាដៃអក្សរសិល្ប៍ដែលជាមរតករបស់ដូនតាយើងដែលបន្សល់ទុកសម្រាប់ឱ្យយើង ក៏ដូចជាកូនចៅជំនាន់ក្រោយយកទៅអភិវឌ្ឍខ្លួន និងអភិវឌ្ឍសង្គមជាតិ។

## II. សេចក្តីអត្ថាធិប្បាយ

រាល់ស្នាដៃអក្សរសិល្ប៍ទាំងអស់សុទ្ធតែបានបង្កប់នូវអត្ថន័យ គុណតម្លៃជាច្រើនទៅ តាមប្រភេទ និងចលនារបស់អក្សរសិល្ប៍នីមួយៗ។ ហើយនៅក្នុងចំណោមចលនាអក្សរសិល្ប៍ទាំងនោះ យើងឃើញចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយមតែងតែបង្កប់នូវតម្លៃល្អៗរបស់ខ្មែរយើងជាច្រើន ដែលជាអត្តសញ្ញាណជាតិ ហើយសុទ្ធសឹងជាពុទ្ធិ និង ជាគតិដ៏ពិសេសៗភ្ជាប់មកជាមួយស្នាដៃអក្សរសិល្ប៍ខ្មែរយើង តួយ៉ាងនៅក្នុងរឿងរាមកេរ្តិ៍ខ្មែរ យើងជាដើម។ អាស្រ័យដូចហេតុនេះ ហើយទើបមានប្រធានលើកឡើងថា "រឿងរាមកេរ្តិ៍មានលក្ខណៈតម្លៃពិសេសក្នុងអក្សរសិល្ប៍ខ្មែរ"។

តើប្រធានដែលបានលើកឡើងខាងលើមានអត្ថន័យដូចម្តេចខ្លះ?

ដើម្បីជាប្រទីបបំភ្លឺដល់ការបកស្រាយគំនិតប្រធានខាងលើ ឱ្យលម្អិតស៊ីជម្រៅយើងគួរយល់ន័យនៃពាក្យគន្លឹះជាមុនសិន។ ពាក្យ "លក្ខណៈ" គឺជាគ្រឿងសម្គាល់នៃអត្តសញ្ញាណបង្ហាញឱ្យឃើញ។ រីឯ "តម្លៃពិសេស" សំដៅទៅលើអ្វីៗដែលល្អក្រៃលែង ដែលមានប្រយោជន៍ដ៏ថ្លៃថ្លា។ ចំណែកឯ "អក្សរសិល្ប៍" មានន័យថាកម្រងអត្ថបទទាំងឡាយដែលតាក់តែងឡើងប្រកបដោយសិល្បវិធីរបស់អ្នកនិពន្ធ។ ដូចនេះ អត្ថន័យប្រធានមានន័យយ៉ាងខ្លីថារឿងរាមកេរ្តិ៍បង្ហាញឱ្យឃើញ នូវអ្វីដែលល្អៗនិងមានប្រយោជន៍នៅក្នុងកម្រងអត្ថបទដែលតាក់តែងឡើងប្រកបដោយ សិល្បវិធីរបស់អ្នកនិព្វខ្មែរយើង។

ជាការពិតណាស់រឿងរាមកេរ្តិ៍គឺជាអត្ថបទរឿងមួយដែលឋិតក្នុងអក្សរសិល្ប៍ខ្មែរត្រូវបានរៀបរៀងដោយអ្នកអង្គម្ចាស់ ស៊ីសុវត្ថិវឌ្ឍឆាយាវង្សបោះពុម្ពផ្សាយដោយវិជ្ជាស្ថាន ពុទ្ធសាសនាបណ្ឌិត្យនៃក្រសួងធម្មការក្នុងគសករាជមួយពាន់ប្រាំមួយរយសាមសិបប្រាំពីរ ឋិតក្នុងចលនាព្រាហ្មណ៍និយមបានឆ្លុះបញ្ចាំងឱ្យឃើញពីតម្លៃជាច្រើនឥតគណនាដែលជារបស់ខ្មែរ ក្នុងអក្សរសិល្ប៍ខ្មែរ។ ជាក់ស្តែងខ្មែរយើងនិយម ឱ្យតម្លៃទៅ លើគ្រូក្នុងការអប់រំ បង្ហាត់បង្រៀនឱ្យសិស្សទៅជាខ្លាំងពូកែ។ តាមដំណើររឿងបាន បញ្ជាក់ថាព្រះរាមមានមហិទ្ធិឫទ្ធិខ្លាំងពូកែដែលអាចយកឈ្នះអស់មាសត្រូវដែលប៉ង មកយាយីបានក៏ដោយសារតែមានគ្រូជាអ្នកបង្ហាត់បង្រៀន គឺមហាឥសីពិស្វាមិត្រ។ បន្ថែមលើសពីនេះទៀតនោះ រាមលក្ខណ៍និងជប្បលក្ខណ៍កុមារទាំងពីរពិតជាមានមហាទិ្ធឫទ្ធិខ្លាំងពូកដែរ។ ដែលអាចយកឈ្នះហនុមាន ដែលជាសេនាជំនិតរបស់ព្រះរាមបានយ៉ាងងាយ ទាំងនេះគឺកើតដោយសារតែទទួលបានពីការអប់រំបង្ហាត់បង្រៀនពីឥសីវេជ្ជប្រិត។ ទន្ទឹមនិងការអប់រំបង្ហាត់បង្រៀននៅក្នុងសាច់រឿងក៏បង្ហាញពីការប្រឡងប្រជែងផងដែល។ ជាទឡ្ហីករណ៍ ពេលដែលសីតាមានវយវឌ្ឍនាការជំពេញរូបពេញរាង ព្រះបាទជនកបានរៀបចំពិធីប្រឡងប្រជែងលើកធ្នូជ្រើសរើសអ្នកដែលមានសមត្ថភាពដើម្បីធ្វើជាកូនប្រសា ជាលទ្ធផលព្រះរាមមានសមត្ថភាពពេញលេញអាចលើកធ្នូបាន ក៏ទទួលបាន

នាងសីតាជាព្រះមហាសី។ យ៉ាងណាមិញនៅក្នុងសាច់រឿងក៏បានឆ្លុះបញ្ចាំងពីពិធីច្រត់ព្រះនង្គ័ល ដែលជាពិធីបុណ្យប្រពៃណីជាតិដែលព្រះរាជាខ្មែរគ្រប់ជំនាន់ប្រារព្ធធ្វើនាថ្ងៃទីបួនរោច ខែពិសាខ ជារាងរាល់ឆ្នាំ ហើយបានបន្តរហូតមកដល់សព្វថ្ងៃនេះ។ ពិធីនេះគេប្រារព្ធដើម្បីបួងសួង សុំសេចក្ដីសុខចម្រើន សុភមង្គល សុំទឹកភ្លៀង និងពិសេសនោះគឺការព្យាករណ៍ផលដំណាំថានឹងទទួលបានទិន្នផលច្រើន ឬតិច ហើយពិធីនេះក៏បង្ហាញពីទឹកព្រះទ័យយកចិត្តទុកដាក់លើប្រជារាស្ត្រក្នុងការប្រកបរបរកសិកម្ម។ តួយ៉ាងព្រះបាទជនកជា ក្សត្រនៃនគរមិថិលា និងជាបិតារបស់ព្រះនាងសីតាបានប្រារព្ធពិធីច្រត់ព្រះនង្គ័ល ដើម្បីសុំសេចក្ដីសុខរបស់ប្រជារាស្ត្រ។ មួយវិញទៀតក៏បង្ហាញពីធ្វើពិធីរៀបអាពាហ៍ពិពាហ៍របស់ខ្មែរយើងគឺប្រព្រឹត្តទៅនៅគេហដ្ឋានខាងស្រី បើយើងមើលទៅក្នុងដំណើររឿង យើងដឹងយ៉ាងច្បាស់ថា ក្រោយពេលដែលព្រះរាមលើកធ្នូទទួលបានជោគជ័យក្នុងការប្រឡងលើកធ្នូហើយ អាពាហ៍ពិពាហ៍របស់ទ្រង់នឹងព្រះនាងសីតា គឺប្រព្រឹត្តទៅនៅនគរមិថិលា ដែលជានគររបស់បិតាព្រះនាងសីតា។ ស្របជាមួយគ្នានេះផងដែរ ខ្មែរយើងនិយមប្រើប្រាស់កោដ្ឋសម្រាប់តម្កល់សពនៅពេលដែលមានមនុស្សស្លាប់។ ជាភស្តុតាង នៅពេលដែលព្រះរាមអស់វិធីដើម្បីយកនាងសីតាមកនគរវិញ ពេលនោះព្រះរាមក៏ធ្វើជាចូលកោដ្ឋបន្លំជាស្លាប់បញ្ឆោតនាងសីតាដើម្បីឱ្យព្រះនាងយាងចូលនគរវិញ។ នេះសឱ្យឃើញពីតម្លៃនៃទំនៀមទម្លាប់របស់ខ្មែរយើងតាំងពីបុរាណកាលមក ឱ្យតែមានមនុស្សស្លាប់ គឺគេតែងតែយកកោដ្ឋសម្រាប់មកតម្កល់សព គ្រាន់តែបច្ចុប្បន្នកោដ្ឋសម្រាប់តម្កល់ជាត់តែប៉ុណ្ណោះ។ យ៉ាងណាមិញនៅក្នុងរឿងនេះដដែលក៏ឆ្លុះបញ្ចាំងពីការផ្ទេររាជសម្បត្តិ ដែលជាធម្មតាការផ្ទេររាជ្យនេះ តាំងពីបុរម្យបុរាណមកគឺបុត្រច្បងជាអ្នកដែលត្រូវស្នងរាជពីព្រះបិតា ដូចដែលព្រះបាទទសរថចង់ផ្ទេររាជសម្បត្តិឱ្យទៅព្រះរាមនេះឯង តែដោយហេតុថាព្រះបាទទសរថធ្លាប់សន្យាជាមួយនាងកៃកេសី ថាបើជួយច្បាំងជាមួយព្រះអាទិត្យឈ្នះនឹងលើកព្រះភិរុតឱ្យឡើងសោយរាជ្យដែលធ្វើឱ្យការផ្ទេររាជ្យនេះមានការប្រែប្រួល។ ជាមួយគ្នានេះដែរតួអង្គនាងសីតាក៏បង្ហាញពីការគោរពពាក្យសច្ចៈដែរ ត្រង់ដែលនាងបានបដិសេដជាមួយនឹងបុត្រថាទាល់តែព្រះរាមសុគតសិន ទើបនាងចូលទៅថ្វាយបង្គំ នេះគឺបង្ហាញឱ្យឃើញថា ការគោរពពាក្យសត្យ ជាចរិកខ្មែរដែលមានតាំងពីយូរលង់ណាស់មកហើយថាខ្មែរ ពិតជាគោរពពាក្យសច្ចៈឥតងាករេ។ ដូចមានសុភាសិតមួយឃ្លាថា "មនុស្សគេយកសម្ដី សំដីជាឯក សម្ដីសជាតិ រនាបបាក់យករនាបជួស សម្ដីហួសគ្មានអ្វីជួសបាន" មានន័យថា ពាក្យសច្ចៈពិតជាមានតម្លៃណាស់ក្នុងសង្គមខ្មែរ។ ទន្ទឹមនឹងនេះផងដែល ការប្រកាន់នូវអំពើអហិង្សាក៏ជាកូនសោរនៃសន្តិភាពផងដែរ។ ជាតឹកតាង ព្រះរាមបានប្រកាន់នូវធម៌អហិង្សាចំពោះម្ដាយចុងដែលជំទាស់នឹងការផ្ទេររាជ្យរបស់ទ្រង់ដោយមិនមានខឹងក្រេវក្រោធជាមួយនឹងនាងកៃកេសីឡើង ដោយព្រះអង្គសុខចិត្តទៅបួសក្នុងព្រៃដប់បួនឆ្នាំតាមសំណើររបស់នាងកៃកេសី ការសម្រេចចិត្តបែបនៅពិតជាបានធ្វើឱ្យប្រទេសជាតិប្រកបដោយសុខសាន្ត ហើយក៏ជាការសម្រេចចិត្តដ៏ត្រឹមត្រូវមួយរបស់ព្រះរាមដែរ។ មួយវិញទៀត

នៅក្នុងសាច់រឿងក៏បង្ហាញពីទឹកចិត្តចំពោះម្តាយមកលើកូន ដូចករណីដែលនាងកៃកេសីដើម្បីកូនសុខចិត្តជួយច្បាំងព្រះរាមជាមួយព្រះអាទិត្យ ក្នុងគោលបំណងជួយព្រះស្វាមីផង និងចង់ឱ្យកូន បានគ្រងរាជ្យផង។ ស្របនឹងនេះផងដែរនាងសីតានៅពេលដែរដឹងដំណឹងថាបុត្ររបស់ខ្លួនត្រូវគេចាប់ឃុំក៏ មានចិត្តអាណិតកូនយ៉ាងក្រៃលែង ព្រោះ ថាកូនធ្លាប់តែមើលថៃ ថ្នាក់ថ្នមបីបាច់ក្នុងរង្វង់ដៃរបស់ខ្លួន។ រឹតតែច្បាស់ទៅទៀត យើងក៏ឃើញនូវសកម្មភាពរបស់នាងសុន្ទគិរី ដែលមានចិត្តស្រឡាញ់និងការពារកូនទូភី ដោយយកកូនទៅសង្ងំនៅក្នុងព្រៃ ដើម្បីឱ្យកូនរួចផុតពីការប៉ងសម្លាប់ពីសំណាក់ ស្តេចក្របី មហិង្សារាជ។ នេះបានបញ្ជាក់ឱ្យឃើញ ពីតម្លៃនៃទឹកចិត្តរបស់ម្តាយដែលមានចំពោះកូន។ ទន្ទឹមនឹងនេះផងដែរ នៅក្នុងសាច់រឿងដដែល ក៏បង្ហាញការគោរពស្រឡាញ់រវាងបងនិងប្អូន ដែលមានចំពោះគ្នា។ ជាភស្តុតាង ព្រះលក្ខណ៍ជាប្អូនដែល គោរពស្រឡាញ់បងតែងតែតាមជួយមើលថៃ និងស្តាប់បងជានិច្ច ដូចនៅពេលដែរព្រះរាមត្រូវចាកចេញពីនគរ ព្រះលក្ខណ៍ក៏សម្រេចចិត្តចាកចេញជាមួយព្រះរាមដោយការពេញចិត្ត និងមិនមានការ បង្ខំឡើយ ដើម្បីតាមជួយទុក្ខធុរៈបងនៅក្នុងព្រៃ។ តួយ៉ាងពេលដែលព្រះរាមធ្វើសង្គ្រាមជាមួយនឹងក្រុងរាពណ៍ ព្រះលក្ខណ៍ចេញច្បាំងដោយមានចិត្តអង់អាចក្លាហាន ដើម្បីជួយបងយកឈ្នះនឹងសត្រូវ។ រីឯព្រះរាមវិញតែងតែមានចិត្តអាណិត ស្រឡាញ់ប្អូនយ៉ាងប៉ុនពេក ដូចត្រង់ករណីពេលដែលព្រះលក្ខណ៍ត្រូវរបួសក្នុងពេលដែលធ្វើសង្គ្រាមជាមួយនឹងកុម្ភការណ៍ ពេលនោះព្រះរាមបានយំសោកដោយអាណិតប្អូនឥតឧបមានិងខិតខំរកវិធីសាស្រ្ត ដើម្បីព្យាបាលប្អូន នេះឆ្លុះបញ្ចាំងឱ្យឃើញពីតម្លៃនៃទឹកចិត្តរវាងបងមានចំពោះប្អូន ហើយប្អូនមានចំពោះបង។ ជាមួយគ្នានេះផងដែរ នៅក្នុងសាច់រឿង បានបង្ហាញពីភាពស្មោះត្រង់ក្នុងសេចក្តីស្នេហា។ ជាតឹកតាង នាងសីតានៅពេលដែលត្រូវក្រុងរាពណ៍ ចាប់ទៅនគរលង្កានោះនាងសីតានៅតែមានភាពស្មោះត្រង់នឹងព្រះស្វាមីឥតងាករេ។ រីឯព្រះរាមវិញនោះ ដើម្បីសេចក្តីស្នេហាសុខចិត្តធ្វើគ្រប់មធ្យោយដូចជាការធ្វើសង្គ្រាមជាដើម។ ទាំងនោះគឺដើម្បីដណ្តើមនាងសីតាមកវិញ នេះក៏ជាការឆ្លុះបញ្ចាំងឱ្យឃើញពីតម្លៃនៃសេចក្តីស្នេហា ពិតជាមានឥទ្ធិពលធ្វើឱ្យមនុស្សហ៊ានធ្វើគ្រប់យ៉ាង ដើម្បីមនុស្សដែរខ្លួនស្រឡាញ់។ យ៉ាងណាមិញក៏ឆ្លុះបញ្ចាំ ពីការចេះជួយ យកអាសារគ្នាក្នុងគ្រាលំបាក ការចេះជួយយកអាសារគ្នានេះដែរ ជាវប្បធម៌មួយដែលខ្មែរយើងមាន តាំងពីយូរលង់ណាស់មកហើយ។ ជាក់ស្តែងនៅពេលដែលសុគ្រីព រត់គេចពីការធ្វើបាបរបស់ពាលីនោះគឺមានតែហនុមានដែលជា ក្មួយទេដែលរតាមមើលថៃសុគ្រីពនិងជួយរកអ្នកខ្លាំងពូកែមកជួយដោះស្រាយឱ្យពូថែមទៀតផង។ ទន្ទឹមនឹងនេះ នៅពេលដែលនាងសីតាគ្មានទីកន្លែងសម្រាប់សំណាក់អាស្រ័យបន្ទាប់ពីព្រះរាមបញ្ជាឱ្យព្រះលក្ខណ៍យកនាងមកសម្លាប់នោះ ឥសីវជ្ជប្រិតបានទទួលនាងសីតាឱ្យមកជ្រងកោន និងមើលការខុសត្រូវលើនាងសីតាយ៉ាងយកចិត្តទុកដាក់។ អំពើទាំងនេះ គឺបង្ហាញពីតម្លៃនៃការចេះជួយគ្នាក្នុងគ្រាដែលលំបាក។ គួរឱ្យតក់សម្គាល់ផងដែរនោះ ក្នុងសាច់រឿងបាន លាតត្រដាងពីការគន់គូរទស្សន៍ទាយ

ក្បួនហោរា ដែលជាជំនឿមួយដែរខ្មែរយើងនិយមប្រើក្នុងការ ចង់ដឹងពីរឿងរ៉ាវផ្សេងៗ ពីហេតុដែលកើតឡើងនូវថ្ងៃខាងមុខ។ គួរជាទីសំអាងផងដែរនោះ នៅក្នុងសាច់រឿងដដែល បានបង្ហាញឱ្យឃើញដូចក្នុងករណី ពិភេកគន់គូរលើជោគវាសនារបស់ក្រុងលង្កានាពេលខាងមុខនឹងត្រូវវិនាស បើសិនជាក្រុងរាពណ៍មិនព្រមដោះលែងនាងសីតាទៅព្រះរាមវិញនោះ ហើយការទស្សន៍ទាយនេះគឺពិតជាត្រឹមត្រូវដូចដែរពិភេកបានគន់គូរប្រមើលមើលពិតមែន។ ស្របជាមួយគ្នាផងដែរ ព្រះរាមបានបានឱ្យហោរាគន់គូរមើលនៅពេលដែលពិភេកមកសុំចុះចូលជាខ្លួន ការគន់គូររបស់ហោរាថាជាការល្អណាស់ដែលពិភេកមកសុំចុះចូលជាមួយនឹងក្រុមរបស់ខ្លួន ព្រោះពិភេកនឹងនាំរឿងល្អៗដល់ការចម្បាំង មួយនេះ។ ទាំងនេះគឺបង្ហាញពីគុណតម្លៃនៃការទស្សន៍ទាយដែលមានតម្លៃណាស់ ក្នុងការឱ្យដឹងពីជោគវាសនា និងរឿងរ៉ាវដែលនឹងកើតឡើងនាពេលខាងមុខ។

សរុបសេចក្តីមក រឿងរាមកេរ្តិ៍ពិតជាមានលក្ខណៈតម្លៃពិសេសក្នុងអក្សរសិល្ប៍ខ្មែរយ៉ាងជ្រាវជ្រៅ ហើយបានបង្ហាញឱ្យឃើញ ពីទំនៀមទម្លាប់ដែរខ្មែរយើងមានតាំងពីបុរាណកាលមក ការគោរពពាក្យសច្ចៈ ការទស្សន៍ទាយ និងការអប់រំរៀនសូត្រខាងសិល្ប៍សាស្រ្ត ទាំងនេះគឺបង្ហាញពីតម្លៃពិសេសៗដែលជាលក្ខណៈមួយរបស់ខ្មែរក្នុងអក្សរសិល្ប៍ខ្មែរយើង។

ឆ្លងតាមរយៈការបកស្រាយប្រធានដែលបានលើកឡើងខាងលើ និងលើកអំណះអំណាងមកបញ្ជាក់រួចមក យើងឃើញថាប្រធានពិតជាល្អ ព្រោះបានបង្ហាញពីលក្ខណៈពិសេសៗ ដែលមានតម្លៃក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរយើង។ ហើយបានបង្កប់នូវតម្លៃអប់រំ ដែលសុទ្ធតែជាជំបូន្មានល្អៗសម្រាប់ជាគតិ ដល់ការរិះគិតពិចារណាក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងម្នាក់ៗនូវអ្វីដែលគួរធ្វើសម្រាប់ខ្លួនឯងគ្រួសារ និងសង្គមជាតិ។

ដូចនេះក្នុងនាមយើងជា សិស្សនិស្សិតយើងគប្បីត្រូវតែខិតខំសិក្សារៀនសូត្រ និងអានសៀវភៅឱ្យបានច្រើន ពិសេសនោះគឺអាននូវស្នាដៃអក្សរសិល្ប៍ខ្មែរយើង ដើម្បីយល់ដឹងពីគុណតម្លៃនៃខ្លឹមសាររបស់អក្សរសិល្ប៍ ហើយទន្ទឹមនិងការអានយើងក៏ត្រូវចូលរួមថែរក្សាស្នាដៃអក្សរសិល្ប៍ ដែលជាមរតករបស់ដូនតាយើងដែរបន្សល់ទុកសម្រាប់ឱ្យយើងក៏ដូចជាកូនចៅជំនាន់ក្រោយយកទៅអភិវឌ្ឍខ្លួន និងអភិវឌ្ឍសង្គមជាតិ។

**III. ឯកសារយោង៖**

*រឿងរាមកេរ្តិ៍ ដែលលើកមកសិក្សានេះដកស្រង់ចេញពីសៀវភៅ សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ (*សម្រាប់ថ្នាក់មធ្យមសិក្សាចំណេះដឹងទូទៅ*) ដែលរៀបរៀង និងចងក្រងដោយ **គង់ សុខហេង។**

**សូមអរគុណ!**